# **សុន្ទរកថា**
# **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
# **នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**
# **ក្នុងពិធីបិទសន្និបាតបូកសរុបការងារឆ្នាំ ២០១៨**
# **និងទិសដៅការងារឆ្នាំ ២០១៩ របស់ក្រសួងការបរទេស**
# **និងសហប្រតិបត្តិការអន្តរជាតិ**

**ថ្ងៃទី ៧ ខែមីនា ឆ្នាំ២០១៩**

--------------------------

*- ឯកឧត្តម លោកជំទាវអស់លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ ជាទីរាប់អាន*

ខ្ញុំមានសេចក្តីរីករាយឥតឧបមាដោយបានមកចូលរួមបិទសន្និបាតប្រចាំឆ្នាំរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការ-អន្តរជាតិ ជាក្រសួងដែលខ្ញុំបានធ្វើជារដ្ឋមន្ត្រីទីមួយក្រោយថ្ងៃរំដោះក្នុងអាយុ ២៧ឆ្នាំ ។ ខ្ញុំនៅចាំបានថា កាលនោះយើងមានធនធានមនុស្សតិចតួច ដែលសុទ្ធសឹងជាអ្នករស់ពីស្លាប់ គ្មានសម្ភារៈមធ្យោបាយ ថវិកាសម្រាប់ធ្វើការងារដូចសព្វថ្ងៃនេះទេ ។

៤០ឆ្នាំបានកន្លងផុតទៅហើយ ។ សភាពការណ៍ពិភពលោក តំបន់ និងកម្ពុជាផ្ទាល់បានផ្លាស់ប្តូរខុសពីមុនឆ្ងាយណាស់ ។ ការផ្លាស់ប្តូរទាំងនេះក៏បាននាំមកនូវបញ្ហាថ្មី ការប្រឈមថ្មី កាលានុវត្ត-ភាពថ្មី ដែលទាមទារឲ្យយើងឆ្លើយតបដោយភាពវាងវៃ បត់បែន និងទាន់ពេល ។

*-ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី*

ជាច្រើនឆ្នាំមកហើយ ដែលពិភពលោកយើងបានងាកបត់មករករបៀបរបបពហុប៉ូល ដំណាលពេលដែលជញ្ជីងកម្លាំង និងអំណាចបានផ្អៀងពីខាងលិច មកខាងកើត ។ ដំណើរវិវត្តមកកាន់របៀបរបបថ្មីនេះបានបណ្តាលឲ្យមានការប្រទាញប្រទង់ ប្រកួតប្រជែងដ៏តានតឹងរវាងមហាអំណាច និងតួអង្គនានាដែលធ្វើឲ្យស្ថានការណ៍តំបន់ និងពិភពលោកវិវត្តផ្លាស់ប្តូរយ៉ាងជ្រាលជ្រៅឆាប់រហ័ស ពិបាកប៉ាន់-ស្មាន ស្មុគស្មាញ និងគ្រោះថ្នាក់បំផុត ទាំងក្នុងទិដ្ឋភាពនយោបាយ សេដ្ឋកិច្ច និងយោធា ។ ដំណើរវិវត្តទៅកាន់ពហុប៉ូលនេះត្រូវទទួលរងនូវការតស៊ូដ៏ស្វិតស្វាញរវាងមហាអំណាចទីមួយ ដែលចង់រក្សាឧត្តមភាពទោលលើពិភពលោក ជាមួយមហាអំណាចនានាដែលកំពុងងើបឡើង និងទាមទារតួនាទីចាត់ចែងកិច្ចការពិភពលោកស្របតាមអំណាច និងសមត្ថភាពថ្មីរបស់ខ្លួន ។ ការងាកចេញពីប្រព័ន្ធពហុភាគីនិយមមកប្រកាន់ឯកតោភាគីនិយមរបស់អាមេរិក ការប្រឈមដាក់គ្នាផ្នែកសេដ្ឋកិច្ច ជាពិសេសរវាងសហរដ្ឋអាមេរិក និងចិន សញ្ញាទាំងឡាយនៃការរត់ប្រណាំងសព្វាវុធឡើងវិញ ការបើកសមរភូមិថ្មីលើវិស័យបច្ចេកវិទ្យាទូរគមនាគមន៍ និងបញ្ញាសិប្បនិមិត្ត សង្គ្រាមពាណិជ្ជកម្មជាដើម គឺជាផ្នែក និងធាតុផ្សំនៃការប្រកួតប្រជែងអំណាចនេះ ។

ប្រទេសតូចៗដូចកម្ពុជាយើង ចៀសមិនផុតឡើយពីការទទួលរងនូវឥទ្ធិពល និងសម្ពាធដែលកើតចេញពីស្ថានភាពខាងលើនេះ ។

*(បន្តិចទៀត ខ្ញុំនឹងធ្វើការវិភាគបកស្រាយលំអិតអំពីស្ថានការណ៍ពិភពលោកក្នុងឆ្នាំ ២០១៩ និងតទៅមុខ ក្នុងកម្មវិធីបិទទ្វាររបស់យើង។)*

ខ្ញុំបានស្តាប់របាយការណ៍សង្ខេបរបស់ឯកឧត្តមឧបនាយក-រដ្ឋមន្ត្រី ប្រាក់ សុខុន រដ្ឋមន្ត្រីការបរទេសនិងសហប្រតិបត្តិការអន្តរ-ជាតិស្តីអំពីសមិទ្ធផលនានាដែលក្រសួងសម្រេចបានក្នុងឆ្នាំកន្លងទៅក្នុងស្ថានភាពដែលកម្ពុជាទទួលរងដោយអយុត្តិធម៌នូវសម្ពាធ និងការជ្រៀតជ្រែកពីខាងក្រៅ ។

ខ្ញុំសុំកោតសរសើរចំពោះសមិទ្ធផលនានាដែលជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ និងមន្ត្រីបុគ្គលិកក្រសួងនៅក្នុងការតស៊ូដើម្បីការពារផលប្រយោជន៍គោលរបស់ប្រទេសជាតិ និងប្រជាជន ទាំងនៅក្នុងប្រទេស ទាំងលើឆាកអន្តរជាតិ។ ខ្ញុំវាយតម្លៃខ្ពស់ចំពោះលទ្ធផលដែលក្រសួងសម្រេចបានក្នុងការអនុវត្តការងារធំៗទាំង ៥ ដែលក្រសួងបានដាក់ចេញកាលពីឆ្នាំ ២០១៧ ។

ពិតណាស់ការងារធំទី ១ គឺការការពារផលប្រយោជន៍ជាតិ ជាពិសេសការពារឯករាជ្យ និងអធិបតេយ្យបានក្លាយជាអាទិភាពចម្បង ក្នុងការងារការទូតរបស់យើង ក្នុងបរិបទនៃការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់កម្ពុជា ការដាក់សម្ពាធកៀបសង្កត់ យកឆន្ទៈប្រទេសធំមកបង្ខំឲ្យយើងទទួលយកគឺជាការគំរាមយ៉ាងធ្ងន់ធ្ងរដល់ឯករាជ្យ អធិបតេយ្យភាព ក៏ដូចជាគំរាមដល់សន្តិភាព និងស្ថិរភាព

របស់ប្រទេសជាតិ ។ ខ្ញុំសុំបញ្ជាក់អះអាងសាជាថ្មីម្ដងទៀតថា កម្ពុជាអរគុណប្រទេស និងស្ថាប័នទាំងអស់ដែលបានជួយឧបត្ថម្ភគាំទ្រដោយស្មោះស្ម័គ្រ ការស្ដារ និងកសាងជាតិឡើងវិញកន្លងមក ប៉ុន្តែយើងនឹងមិនប្ដូរអធិបតេយ្យភាពរបស់យើងជាមួយនឹងជំនួយណាជាដាច់ខាត ។ យើងត្រូវបន្តការពារនូវសិទ្ធិអធិបតេយ្យរបស់យើង ក្នុងការធ្វើសេចក្ដីសម្រេចដោយឯករាជ្យ ដើម្បីការពារប្រយោជន៍គោលរបស់ជាតិយើង ការពារសន្តិភាព ភាពសុខសាន្តរបស់ប្រជាជនប្រឆាំងតបនឹងរាល់ការប៉ុនប៉ងផ្ដួលរំលំរដ្ឋាភិបាលស្របច្បាប់ដែលកើតចេញពីឆន្ទៈ និងការគាំទ្ររបស់ប្រជាជនភាគច្រើនលើសលុប ។ ខ្ញុំសូមគាំទ្រដល់ការប្ដេជ្ញារបស់ក្រសួងការបរទេស និងសហប្រតិបត្តិ-ការអន្តរជាតិ និងគ្រប់ស្ថានបេសកកម្មរបស់យើងនៅក្រៅប្រទេសក្នុងការតស៊ូដើម្បីការពារយុត្តិធម៌ជូនរាជរដ្ឋាភិបាលជូនប្រទេសជាតិ និងប្រជាជនកម្ពុជាយើង ។

នៅចំពោះមុខសភាពការណ៍តំបន់ និងពិភពលោកដែលកំពុងវិវត្តប្រែប្រួលយ៉ាងឆាប់រហ័ស ស្មុគស្មាញមិនអាចប៉ាន់ស្មានបាន និងប្រកបដោយគ្រោះថ្នាក់នោះ ការកាច់ចង្កូតនាវាកម្ពុជា ទាមទារការថ្លឹងថ្លែង និងការប្រុងប្រយ័ត្នខ្ពស់ ។ ត្រង់នេះហើយដែលការអនុវត្តនូវនយោបាយការបរទេសប្រកបដោយភាពបត់បែន វាងវៃ តបទៅនឹងការប្រែប្រួល និងសម្ពាធភូមិសាស្ត្រនយោបាយ និងការប្រកួតប្រជែងដ៏តានតឹងរបស់មហាអំណាចនានានោះ មានសារៈសំខាន់បំផុតដើម្បីរក្សាឲ្យបាននូវលក្ខខណ្ឌចាំបាច់នានាសំដៅការពារសន្តិភាព ស្ថិរភាព ដំណើរអភិវឌ្ឍន៍ប្រទេសជាតិ ដោយឈរលើគោលការណ៍អព្យាក្រឹត្យ អចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ ។

គោលនយោបាយក្នុងស្រុក និងគោលនយោបាយការបរទេស បំពេញឲ្យគ្នាទៅវិញទៅមក ហើយមានទំនាក់ទំនងមិនអាចកាត់ផ្ដាច់ពីគ្នាបានឡើយ ។ អនុវត្តតាមបាវចនាពីររបស់រាជរដ្ឋាភិបាល ពោលគឺ «កែទម្រង់ខាងក្នុង និងបង្កើនមិត្តខាងក្រៅ ក្នុងស្មារតីពង្រឹងឯករាជ្យ និងអធិបតេយ្យភាពជាតិ» យើងនឹងបន្តបង្កើនទំនាក់ទំនង និងសកម្ម-ភាពការទូតដើម្បីពង្រឹង និងពង្រីកចំណងមិត្តភាព និងសហប្រតិបត្តិ-ការជាមួយប្រទេសនានានៅលើលោកឲ្យកាន់តែច្រើនថែមទៀត ដើម្បីលើកស្ទួយផលប្រយោជន៍ និងកិត្យានុភាពជាតិកម្ពុជា ។

ការផ្លាស់ប្ដូរពីរបៀបធ្វើការងារការទូតប្រពៃណី មកជាការងារការទូតដែលផ្ដោតសារៈសំខាន់ដល់ការលើកស្ទួយសេដ្ឋកិច្ច វប្បធម៌ និងទេសចរណ៍ គឺជាការឆ្លើយតបយ៉ាងត្រឹមត្រូវទៅនឹងសភាពការណ៍ថ្មីដែលទាមទារឲ្យអ្នកការទូតយើង រួមវិភាគទានកាន់តែធំដល់ការជំរុញសេដ្ឋកិច្ច និងវិនិយោគ ទាក់ទាញទេសចរ និងការផ្សព្វផ្សាយវប្បធម៌ជាតិខ្មែរ ។ យើងត្រូវប្រែការប្រឈមទាំងឡាយឲ្យក្លាយជាកាលានុវត្តភាពដើម្បីពង្រឹងខ្លួនឯង រស់ខ្លួនឯង និងអភិវឌ្ឍខ្លួនឯង ដោយកាត់បន្ថយការពឹងពាក់លើជំនួយពីខាងក្រៅឲ្យនៅតិចបំផុតដែលអាចធ្វើទៅបាន ។

យើងក៏នឹងបន្តរួមវិភាគទានរបស់យើងក្នុងបុព្វហេតុសន្តិភាព ស្ថិរភាព និងក្នុងការប្រយុទ្ធដោះស្រាយការប្រឈមនានានៅលើលោក តួយ៉ាងប្រឆាំងនឹងភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែន ការប្រែប្រួលធាតុ-អាកាស ការជួញដូរគ្រឿងញៀន ការជួញដូរមនុស្ស ជំងឺឆ្លង ។ល។

ការងារដែលយើងកំពុងធ្វើក្នុងការត្រៀមរៀបចំធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំអាស៊ី-អឺរ៉ុបលើកទី ១៣ នៅឆ្នាំ ២០២០ គឺជាការចូលរួមចំណែកលើបុព្វហេតុខាងលើតាមរយៈការគាំទ្រពហុភាគីនិយមផង និងការលើកស្ទួយតួនាទីរបស់កម្ពុជាក្នុងការកំណត់របៀបវារៈអន្តរតំបន់ផង ។

ដូចខ្ញុំបានបញ្ជាក់អះអាងជូនឯកឧត្តមអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ នៅទីក្រុងញូវយ៉កកន្លងមកថា កម្ពុជាក៏នឹងបន្ត ហើយនឹងបង្កើនការចូលរួមក្នុងបេសកកម្មរក្សាសន្តិភាពនៅទីណាដែលមានតម្រូវការ ។ នេះគឺជាវិភាគទានដ៏ថ្លៃថ្នូរបំផុតរបស់កម្ពុជាដែលជាប្រទេសធ្លាប់រងទុក្ខវេទនាដោយសារសង្គ្រាម ។

ខ្ញុំបានស្តាប់ និងសុំកោតសរសើរចំពោះគំនិតផ្តួចផ្តើម និងសកម្មភាពទាំងឡាយសំដៅកែទម្រង់ការងារក្រសួងឲ្យប្រកបដោយប្រសិទ្ធភាព និងសមធម៌។ ការធ្វើឲ្យប្រសើរឡើងនូវលក្ខខណ្ឌការងាររបស់មន្ត្រីបុគ្គលិកយើង ការបង្កើនប្រាក់បៀវត្សជូនមន្ត្រីការទូតនៅបរទេស ការបង្កើនថវិកាដំណើរការស្ថានបេសកកម្ម១០% និងការផ្តល់ប្រាក់រង្វាន់សម្រាប់មន្ត្រីក្នុងស្រុក សុទ្ធសឹងជាវិធានការដែលខ្ញុំបានគាំទ្រ។ ការសម្ពោធដាក់ឲ្យដំណើរការវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ កាលពីឆ្នាំទៅមិញក៏នឹងរួមចំណែកដ៏សំខាន់បំផុតក្នុងការបង្កើត និងពង្រីកចំណេះដឹង ទទួលបានបទពិសោធន៍ថែមទៀតដើម្បីកសាងជួរអ្នកការទូតយើងដែលប្រកបដោយវិជ្ជាជីវៈមានសមត្ថភាពខ្ពស់ និងទឹកចិត្តស្មោះត្រង់ក្នុងការការពារផលប្រយោជន៍ស្នូលរបស់ប្រទេស និងប្រជាជនយើង។

នយោបាយការបរទេសគឺជាយុទ្ធសាស្ត្រ ហើយការទូតគឺជាមធ្យោបាយ និងវិធីសាស្ត្រ ក្នុងការលើកស្ទួយផលប្រយោជន៍ជាតិឲ្យសមស្របតាមយុទ្ធសាស្ត្រនោះ។ ដូច្នេះការយកចិត្តទុកដាក់លើធនធានមនុស្សអ្នកការទូតដែលជាអ្នកអនុវត្តផ្ទាល់នូវនយោបាយការបរទេសរបស់រាជរដ្ឋាភិបាលគឺមានសារៈសំខាន់ខ្លាំង។

ការតំឡើងឋានៈ តែងតាំងមុខតំណែង ដោយផ្អែកលើសមត្ថភាព ឥរិយាបថការងារ ភាពអំណត់ព្យាយាម តាមទិសស្លោក "កុំយកលុយទៅរកប៉ុស្តិ៍ កុំយកប៉ុស្តិ៍ទៅរកលុយ"នោះ គឺជាកត្តាកំណត់សំខាន់បំផុតដើម្បីបង្កើតបាននូវតម្លាភាព សមធម៌ និងបរិយាកាសមួយដែលលើកទឹកចិត្តដល់មន្ត្រីបុគ្គលិកទាំងអស់ដែលខិតខំប្រឹងប្រែងបំពេញការងារ ។

ជាថ្មីម្តងទៀត ខ្ញុំសុំកោតសរសើរសមិទ្ធផលទាំងឡាយដែលថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិកយើងទាំងអស់សម្រេចបានក្នុងឆ្នាំកន្លងទៅ ។

*(ខ្ញុំស្នើអ្នកសារព័ត៌មានទាំងអស់ចាកចេញពីសាលប្រជុំ ដើម្បីខ្ញុំធ្វើការណែនាំការងារបន្តដល់អង្គសន្និបាត។)*